# II-រាជរដ្ឋាភិបាលកម្ពុជា

## ១-អនុក្រឹត្យ

## អនុក្រឹត្យ លេខ ០៦ អនក្រ.បក

## ស្តីពី

## ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកណ្តាល ទុកសំរាប់ប្រជាពលរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តកណ្តាលដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែក លេខ ២ . ១៣. ១៤ និងលេខ ១៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តកណ្ដាល និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកណ្ដាល ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៨ ៧៧២ | ៦ ៣២២ | ២ ៤៥០ | ៧២ ០០ | |
| ២ | ១៧ ២៥០ | ១៧ ២៥០ | ០ | ១០០ | លុបចោល |
| ៣ | ១២ ៨៦៩ | ១០ ១៥២ | ២ ៧១៧ | ៧៨ ៨៨ | |
| ៤ | ៩ ៦៤៨ | ៧ ៥១៥ | ២ ១៣៣ | ៧៧ ៩០ | |
| ៥ | ១០ ៥៥៦ | ៧ ៦៥៤ | ២ ៩៤២ | ៧២ ២៣ | |
| ៦ | ២៧ ៥៨០ | ១៨ ៣០០ | ៩ ២៨០ | ៦៦ ៣៥ | |
| ៧ | ៧ ៨៧០ | ៧ ០០៣ | ៨៦៧ | ៨៨ ៩៨ | |
| ៨ | ២ ៤០៥ | ១ ៨២៤ | ៥៨១ | ៧៥ ៨៤ | |
| ៩ | ៧ ១៦២ | ៤ ៥៨៥ | ២ ៥៧៧ | ៦៤ ០០ | |
| ១០ | ៣ ៧៦៨ | ១ ៣៣៤ | ២ ៤៣៤ | ៣៥ ៤០ | |
| ១១ | ៦ ៦៩៧ | ២ ៩១១ | ៣ ៧៨៦ | ៤៣ ៤៦ | |
| ១២ | ៩ ៨៤៩ | ៤ ១៦៧ | ៥ ៦៨២ | ៤២ ៣០ | |
| ១៣ | ៣ ៥២២ | ៣ ៥២២ | ០ | ១០០ | លុបចោល |
| ១៤ | ៦ ៤៥០ | ៦ ៤៥០ | ០ | ១០០ | លុបចោល |
| ១៥ | ១ ៥៥២ | ១ ៥៥២ | ០ | ១០០ | លុបចោល |
| ១៦ | ១២ ៣២២ | ៧ ៧៣៧ | ៤ ៥៨៥ | ៦២ ៧៩ | |
| ១៧ | ៩ ០៨៤ | ៦ ២៤៧ | ២ ៨៣៧ | ៦៨ ៧៦ | |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ១២ ៨២៩ | ៧ ៣២៧ | ៥ ៥០២ | ៥៧ ១១ | |
| ១៩ | ៩ ៥០៣ | ៦ ២៣៦ | ៣ ២៦៧ | ៦៥ ៦២ | |
| សរុប ១៩ | ១៧៩ ៧២៨ | ១២៨ ០៨៨ | ៥១ ៦៤០ | ៧១ ២៦ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំព័ទ្ធយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ.ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**